## ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៣០៤ អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពី
## ការកែសម្រួល មាត្រា៣២ មាត្រា៣៦ និងមាត្រា៤០ នៃអនុក្រឹត្យលេខ១២ អនក្រ.បក ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ និងមាត្រា ១៣ថ្មី នៃអនុក្រឹត្យលេខ២២១ អនក្រ.បក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីឯកសណ្ឋាន ស្លាកសញ្ញា និងទង់ជ័យ នៃកងយោធពលខេមរភូមិន្ទ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្ដីពីការកែសម្រួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ២៩អនក្រ.បក ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០០២ ស្ដីពីបទវិន័យទូទៅសម្រាប់កងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ១២អនក្រ.បក ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ ស្ដីពីឯកសណ្ឋាន ស្លាកសញ្ញា និងទង់ជ័យនៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ២២១អនក្រ.បក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីកែសម្រួលមាត្រា៧ មាត្រា១៣ និងមាត្រា១៩ នៃអនុក្រឹត្យលេខ១២អនក្រ.បក ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ ស្ដីពីឯកសណ្ឋាន ស្លាកសញ្ញា និងទង់ជ័យនៃកងយោធពលខេមរភូមិន្ទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រាមួយ ៈ-**

មាត្រា៣២ មាត្រា៣៦ និងមាត្រា៥០ នៃអនុក្រឹត្យលេខ ១២អនក្រ.បក ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ និងមាត្រា១៣ថ្មី នៃអនុក្រឹត្យលេខ ២២១អនក្រ.បក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីឯកសណ្ឋាន ស្លាកសញ្ញា និងទង់ជ័យនៃកងយោធពលខេមរភូមិន្ទ ត្រូវបានកែសម្រួលដូចតទៅៈ

**មាត្រា១៣ ៈ- ថ្មី(មួយ)**

ត្រូវបានរៀបចំឯកសណ្ឋានលេខ៤ សម្រាប់កងទ័ពជើងទឹក និងមូកកាស្កេតនារី ប្រភេទទ័ពនិងកងរាជអាវុធហត្ថសម្រាប់ប្រើប្រាស់ជាមួយឯកសណ្ឋានលេខ២(វ៉ារី) និងឯកសណ្ឋានលេខ៣(សាហារីយែន) ដែលមានរូបភាព និងទម្រង់គំរូដូចខាងក្រោមៈ

**១.ឯកសណ្ឋានលេខ៤ កងទ័ពជើងទឹក**

**១.១ ឯកសណ្ឋានថ្នាក់ឧត្តមនាវី**

**ក. គំរូទី០១**

- អាវបុរសដៃខ្លីពណ៌ស កឧបមានប៉ូលស្មាទាំងសងខាង កាត់ស្រុងវែងដាក់ក្នុងខោ មានហោប៉ៅពីរ ដេរបង្កប់ចំកណ្តាល ដេរបត់ផ្នត់មួយមានគម្របរាងស្លឹកពោធិ៍ ឡេវពណ៌ស ធម្មតា
- ខោជើងវែងពណ៌ស កាត់ទម្រង់គំរូដូចឯកសណ្ឋានលេខ៣
- ចំពោះនារីអាវដូចបុរស តែកាត់តាមរាងដងខ្លួន ខោជើងវែងពណ៌ស ឬសំពត់ហ្ស៊ីបពណ៌ស ត្រឹមក្បាលជង្គង់
- មួកហ្វ៊ុកកីពណ៌ខៀវទឹកប៊ិកចាស់ ប៉ាក់រូបព្រះសង្ហារពណ៌មាស តាមលំដាប់ថ្នាក់ដូចកងទ័ពជើងគោក
- ខ្សែក្រវ៉ាត់ពណ៌ស ក្បាលខ្សែក្រវ៉ាត់ធ្វើពីលោហធាតុពណ៌មាស
- ស្រោមជើង និងស្បែកជើងស្បែក កខ្លី ចងខ្សែ ពណ៌ស។

**ខ. គំរូទី០២** ដូចគំរូទី០១ ខុសត្រង់ៈ

- ខោ និងសំពត់ មានពណ៌ខៀវទឹកប៊ិកចាស់
- ខ្សែក្រវ៉ាត់ ស្រោមជើង និងស្បែកជើងស្បែក មានពណ៌ខ្មៅ។

**១.២ ឯកសណ្ឋានថ្នាក់វរនាវី** ដូចឯកសណ្ឋានថ្នាក់ឧត្តមនាវី

**១.៣ ឯកសណ្ឋានថ្នាក់អនុនាវី** ដូចឯកសណ្ឋានថ្នាក់ឧត្តមនាវី

**១.៤ ឯកសណ្ឋានថ្នាក់នាយនាវីរង និងពលនាវី**

- អាវការងារដៃវែង ពណ៌ស កអាវទម្លាក់មកក្រោមរាងជាកន្សែងវែង ប្រវែង២៥ស.ម ជុំវិញកអាវមានឆ្នូត៣ពណ៌ខៀវ ឆ្នូតនីមួយៗមានទំហំ ០៨ម.ម
- ខោជើងវែងពណ៌ស ស្បែកជើងស្បែកកខ្លីពណ៌ស ចងខ្សែ ស្រោមជើងពណ៌ស
- ខ្សែក្រវ៉ាត់ពណ៌ស ក្បាលខ្សែក្រវ៉ាត់ធ្វើពីលោហធាតុលាតពណ៌មាស



គេហទំព័រ ឯកសារមន្ត្រីរាជការ - https://t.me/oa_channel

- មួកម៉ាតឺឡូពណ៌ស ជើងមួកពណ៌ខៀវ លើជើងមួកមានសរសេរអក្សរពណ៌សថា **«កងទ័ពជើងទឹក»** កម្ពស់អក្សរ១៥ម.ម។ ជើងមួកខាងក្រោយដែក មានខ្សែពីរសម្រាប់ចងនៅកន្ទុយខ្សែមានរាងកន្ទុយត្រី។

**២.មួកកាស្កេតនារី ប្រភេទទ័ព និងកងរាជអាវុធហត្ថ**

**+ រូបភាពនិងខ្នាត**

- មួកកាស្កេតពណ៌តាមប្រភេទទ័ពមានក្បាលលើកម្ពស់៩០ម.ម ហាមមួកខាងមុខ និងខាងក្រោយប្រវែង ៥០ម.ម បត់ពាក់កណ្តាលទៅខាងក្រោយ ទុកហាមត្រង់ទៅខាងមុខ

- រូបព្រះសង្ហារពណ៌មាស ដេប៉ះ នៅចំកណ្តាលមួក

- ខ្សែវ័ណ្ណខាងមុខ វេញចូលគ្នាពណ៌មាស មានទំហំ ១០ម.ម និងឡេវពណ៌មាសរូបព្រះសង្ហារមានអង្កត់ផ្ចិត ១៨ម.ម។ នៅចំហៀងសងខាង ក្បាលលើមួក មានរន្ធខ្យល់ចេញចូល ម្ខាងចំនួន២។

**២.១ សម្រាប់កងទ័ពជើងគោក**

ពណ៌គ្រេអ៊ី លក្ខណៈទៅតាមឋានន្តរសក្តិដូចខាងក្រោម៖

**+ ថ្នាក់ឧត្តមសេនីយ៍**

- នៅលើហាមមួកខាងមុខ មានប៉ាក់ក្បាច់ផ្កាភ្ញីទេស ធ្វើពីអំបោះពណ៌មាស ពីចុងម្ខាងដល់ចុងម្ខាង (ចំកណ្តាលមានកម្ពស់ ៣២ម.ម)។

**+ ថ្នាក់វរសេនីយ៍**

- នៅលើហាមមួកខាងមុខ មានប៉ាក់ក្បាច់ផ្កាភ្ញីទេស ធ្វើពីអំបោះពណ៌មាស ទុកចន្លោះពីជើងមួកម្ខាង៥ស.ម (ចំកណ្តាលមានកម្ពស់ ៣២ម.ម)។

**+ ថ្នាក់អនុសេនីយ៍**

- មានប៉ាក់ឆ្នូតពណ៌មាស លើគែមហាមមួក ទំហំ ១០ម.ម។

**+ ថ្នាក់នាយទាហានរង និងពលទាហាន**

- គ្មានក្បាច់ផ្កាភ្ញីទេស និងឆ្នូតអ្វីទាំងអស់។

- ប្រើប្រាស់បានជាមួយឯកសណ្ឋានលេខ២ នៅពេលចេញទៅបំពេញបេសកកម្មក្រៅប្រទេស

**២.២ សម្រាប់កងទ័ពជើងទឹក**

ក្បាលលើពណ៌ស និងចាប់ពីពាក់កណ្តាលក្បាលលើមួក មកខាងមុខ រាងជាត្រីកោណស្រួចទៅខាងលើដល់ដំបូលមួក មានពណ៌ខៀវទឹកប៊ិក។ មានលក្ខណៈដូចមួកកងទ័ពជើងគោក តាមឋានន្តរសក្តិ។

**២.៣ សម្រាប់កងទ័ពជើងអាកាស**

ពណ៌ខៀវផ្ទៃមេឃ មានលក្ខណៈដូចទៅនឹង មួកកងទ័ពជើងគោក។

**២.៤ សម្រាប់កងរាជអាវុធហត្ថ**

ពណ៌ប្រផេះ មានលក្ខណៈដូចទៅនឹង មួកកងទ័ពជើងគោក។

រូបភាពឯកសណ្ឋានលេខ៤ កងទ័ពជើងទឹក និងមួកកាស្កេតនារី សម្រាប់ប្រភេទទ័ព កងរាជអាវុធហត្ថ មានគំរូដូចក្នុងឧបសម្ពន្ធនៃអនុក្រឹត្យនេះ។

## មាត្រា៣២ – ថ្មី

ត្រូវបានរៀបចំឯកសណ្ឋានលេខ៥ សម្រាប់កងរាជអាវុធហត្ថ ដែលមានរូបភាព និងទម្រង់គំរូដូចខាងក្រោម៖

- ខោ អាវ ពណ៌ទឹកប៊ិកចាស់ កាត់ទម្រង់គំរូដូច ឯកសណ្ឋានប្រយុទ្ធកងទ័ពជើងគោក តែប្រើខ្សែចងចង្កេះ

- មួកដែក មួកបេរ៉េ ឬមួកហាម ពណ៌ខៀវទឹកប៊ិកចាស់

- ស្បែកជើងស្បែក កវែងចងខ្សែពណ៌ខ្មៅ និងស្រោមជើងពណ៌ខ្មៅ។

ឯកសណ្ឋាននេះប្រើគ្រប់ឋានន្តរសក្តិ។

រូបភាពឯកសណ្ឋានលេខ៥ សម្រាប់កងរាជអាវុធហត្ថ មានគំរូដូចក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

## មាត្រា៣៦ – ថ្មី

ត្រូវបានរៀបចំឯកសណ្ឋានកងត្រៃទ័ព និងឯកសណ្ឋានសិល្បៈកងយោធពលខេមរភូមិន្ទ ដែលមានរូបភាព និងទម្រង់គំរូដូចខាងក្រោម៖

### ១. ឯកសណ្ឋានកងត្រៃទ័ព

- អាវកុដ ពណ៌ស មានហោប៉ៅ៤ ខាងលើ២ដេរប៉ះ មានគម្របរាងស្លឹកពោធិ៍ មានឡេវរូបព្រះសង្ខារពណ៌មាស ខាងក្រោម២ដេរបង្កប់គម្របហោប៉ៅរាងស្លឹកពោធិ៍ មានឡេវរូបព្រះសង្ខារពណ៌មាស។ ឡេវអាវរូបព្រះសង្ខារពណ៌មាសចំនួន៦គ្រាប់ កអាវមានប៉ាក់ភ្ញីទេសពណ៌មាស ទំហំ៣០ម.ម ចុងដៃអាវមានប៉ាក់ភ្ញី ពណ៌មាស ទំហំ២០ម.ម មានឆ្នូតបង្កង់២ ទំហំ១០ម.ម ពណ៌មាស និងវ័ណ្ឌ១នៅលើបង្កង់ពណ៌មាស

- មួកកាស្កេត ពណ៌ស ជើងមួកពណ៌ខ្មៅ លម្អដោយខ្សែវ័ណ្ឌពណ៌មាស មានរូបព្រះសង្ខារពណ៌មាស ហាមមួកពណ៌ខ្មៅ រំលេចដោយក្បាច់ភ្ញីពណ៌មាស មានខ្សែស្បែកពណ៌ខ្មៅរឹបនឹងចង្កា

- ខោជើងវែង ពណ៌ខ្មៅ មានឆ្នូត២ពណ៌លឿង ឆ្នូតនីមួយៗមានទំហំ២០ម.ម ជើងខោរាងស្ដួចចាប់ពីក្បាលជង្គង់ចំទៅក្រោម

- ស្បែកជើងកវែង ពណ៌ខ្មៅ ប្រវែងត្រឹមក្បាលជង្គង់

- សក្តិស្មាពណ៌មាស មានរឹមព័ទ្ធជុំវិញ

- ខ្សែឥស្សរិយយស ពណ៌មាស(ចំនួន៣ខ្សែវេញបញ្ចូលគ្នា ពីស្មាមកព្យួរនឹងឡេវអាវទី២ ចាប់ពីត្រឹមឡេវអាវមកសល់ ១ខ្សែបន្ដោងក្បាលខ្សែ មានតែ១)ស្លាកឈ្មោះ រូបឋានុមានពាក់នៅលើហោប៉ៅអាវខាងស្ដាំ គ្រឿងឥស្សរិយយស ពាក់នៅលើហោប៉ៅអាវខាងឆ្វេង

- ខ្សែក្រវ៉ាត់ធំធ្វើពីស្បែកពណ៌ស ទំហំ៧០ម.ម ក្រវ៉ាត់ពីលើអាវ និងស្រោមដៃពណ៌ស។

### ២. ឯកសណ្ឋានសិល្បៈកងយោធពលខេមរភូមិន្ទ

#### ២.១ ឯកសណ្ឋានធំលេខ១

**+ រូបភាព និងខ្នាត**

- អាវកុដ ពណ៌ខៀវទឹកប៊ិក មានហោប៉ៅ៤ ខាងលើ២ដេរប៉ះ និងខាងក្រោម២ដេរបង្កប់គម្របហោប៉ៅរាងស្លឹកពោធិ៍ មានឡេវរូបព្រះសង្ខារពណ៌មាស។ ឡេវអាវរូបព្រះសង្ខារពណ៌មាសចំនួន៥គ្រាប់ កអាវមានប៉ាក់ភ្ញីទេស ពណ៌មាស ទំហំ៣០ម.ម ចុងដៃអាវមានប៉ាក់ភ្ញីទេសពណ៌មាស ទំហំ៦០ម.ម មាន



គេហទំព័រ ឯកសារមន្ត្រីរាជការ - https://t.me/oa_channel

ឆ្នូតបង្កង់៣ ទំហំ២០ម.មពណ៌មាស

- មួកកាស្កេត ពណ៌ខៀវទឹកប៊ិក ជើងមួកពណ៌ក្រហម លម្អដោយខ្សែវ័ណ្ឌពណ៌មាស មានរូបព្រះសង្ឃារពណ៌មាស។ នៅខាងក្រោម រូបព្រះសង្ហារមានវ័ណ្ឌពណ៌ក្រហម ហាមមួកពណ៌ខ្មៅ រំលេចដោយក្បាច់ភ្ញីពណ៌មាស (ដូចមួកកងកិត្តិយស-ត្រៃទ័ព)

- ខោជើងវែង ពណ៌ស មានឆ្នូត២ពណ៌មាស ឆ្នូតនីមួយៗមានទំហំ១០ម.ម

- សម្រាប់នារី សំពត់បត់ត្រឹមក្បាលជង្គង់ ពណ៌ស មានឆ្នូត២ពណ៌មាស ឆ្នូតនីមួយៗមានទំហំ១០ម.ម

- សក្តិស្មាមានផ្ទៃពណ៌មាស ជាប្រភេទសក្តិកិត្តិយស មានរឹមពណ៌មាសព័ទ្ធជុំវិញ ខាងក្បាលមានរូបមកុដ ធ្វើពីលោហធាតុពណ៌មាស ខាងចុងមានរូបឆត្រូត ពណ៌មាស ប៉ាក់ភ្ជាប់និងផ្ទៃសក្តិ

- ស្រោមជើង និងស្បែកជើងស្បែក កខ្លី ចងខ្សែ ពណ៌ខ្មៅ

- ខ្សែឥស្សរិយយស ពណ៌មាស(ចំនួន៣ខ្សែវេញបញ្ចូលគ្នា ពីស្មាមកព្យួរនឹងឡេវអាវទី២ ចាប់ពីត្រឹមឡេវអាវមកសល់ ១ខ្សែបន្តោងក្បាលខ្សែ មានតែ១) គ្រឿងឥស្សរិយយស និងមេដាយព្យួរពាក់នៅលើហោប៉ៅអាវឆ្វេង

- ខ្សែក្រវ៉ាត់ធំពណ៌មាស ទំហំ៦៥ម.ម ក្បាលខ្សែក្រវ៉ាត់មានរូបសញ្ញាតំណាងតន្ត្រី (LYRE) ធ្វើពីលោហធាតុធាតុពណ៌មាស ក្រវ៉ាត់លើអាវ។

+ **ការប្រើប្រាស់** សម្រាប់ប្រើក្នុងពិធីសម្តែងផ្លូវការ ក្នុង និងក្រៅប្រទេស។

**២.២ ឯកសណ្ឋានលេខ៣**(សាហារីយែន)

+ **រូបភាពនិងខ្នាត**

- អាវលេខ៣ (សាហារីយែន) កបើកផែក មានវ័ណ្ឌពណ៌មាស ទំហំ៥ម.ម ព័ទ្ធជុំវិញកអាវ មានហោប៉ៅ៤ ខាងលើ២ និងខាងក្រោម២ដេរប៉ះ មានគម្របរាងស្លឹកពោធិ៍ មានឡេវរូបព្រះសង្ហារ ពណ៌មាស។ ឡេវអាវរូបព្រះសង្ហារចំនួន៩គ្រាប់។ នៅចុងកអាវមានលោហធាតុ ពណ៌មាស តំណាងសិល្បៈ(LYRE លោហធាតុ សិល្បៈ)។ ដៃអាវខាងលើរាងកែង និងចុងដៃអាវមានប៉ាក់ភ្ញីទេសពណ៌មាស ទំហំ២០ម.ម។ ក្រោមស្មាស្តាំមាន ស្លាកសញ្ញាកងយោធពលខេមរភូមិន្ទ ក្រោមស្មាឆ្វេងមានស្លាកសញ្ញា សិល្បៈកងយោធពលខេមរភូមិន្ទ

- មួកកាស្កេត ជើងមួកពណ៌ក្រហម លម្អដោយខ្សែវ័ណ្ឌពណ៌មាស មានរូបព្រះសង្ហារពណ៌មាស។ នៅខាងក្រោម រូបព្រះសង្ហារមានវ័ណ្ឌពណ៌ក្រហម ហាមមួកពណ៌ខ្មៅ រំលេចដោយក្បាច់ភ្ញីពណ៌មាស (ដូចមួកកងកិត្តិយស-ត្រៃទ័ព)

- ខោជើងវែង មានឆ្នូត២ពណ៌មាស ឆ្នូតនីមួយៗមានទំហំ១០ម.ម

- សម្រាប់នារី សំពត់បត់ត្រឹមក្បាលជង្គង់ មានឆ្នូត២ពណ៌មាស ឆ្នូតនីមួយៗមានទំហំ១០ម.ម

- សក្តិស្មាដូច ឯកសណ្ឋាន កកុដ

- មួក អាវ អាវយឺតក្នុងដៃខ្លី ខោ និងសំពត់(ចំពោះនារី) មានពណ៌ត្រែអ៊ី

- ស្រោមជើង និងស្បែកជើងស្បែក កខ្លី ចងខ្សែ ពណ៌ខ្មៅ

- សញ្ញាប្រភេទទ័ព ស្លាកឈ្មោះ រូបហនុមានពាក់នៅលើហោប៉ៅអាវខាងស្តាំ គ្រឿងឥស្សរិយយសការងារ (ក្បាលមេដាយ) ពាក់នៅលើហោប៉ៅអាវឆ្វេង។

+ **ការប្រើប្រាស់** ប្រើសម្រាប់ក្នុងពិធីសម្តែង ក្នុង ក្រៅប្រទេស និងចូលរួមពិធីផ្សេងៗ។

រូបភាពឯកសណ្ឋានសិល្បៈកងយោធពលខេមរភូមិន្ទ មានគំរូដូចក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា៤០ – ថ្មី**

ទង់ជ័យ និងទង់ស្លាប័ន និងកងឯកភាព នៃកងយោធពលខេមរភូមិន្ទ មានដូចខាងក្រោម៖

**១. ទង់ជ័យ កងយោធពលខេមរភូមិន្ទ**

ប្រើប្រាស់សម្រាប់បំពាក់ជូនប្រតិបត្តិការសមរភូមិ រាងចតុកោណកែង ផ្ទៃពណ៌ក្រហម។ នៅផ្នែកខាងលើ ជ្រុងខាងឆ្វេងនៃផ្ទៃទង់មានរូបសញ្ញា **កងយោធពលខេមរភូមិន្ទ** (រូបហនុមាន) មានកម្ពស់ ៣៦ស.ម និងទទឹង២២ស.ម។ នៅចំកណ្តាលមាន **រូបសញ្ញាសមរភូមិ** នៅខាងក្រោមរូបសញ្ញា មានសរសេរអក្សរពណ៌មាស **ឈ្មោះសមរភូមិ** កម្ពស់អក្សរ១២ស.ម។ ក្បាលដងទង់រាងជាសាជីស្រួចទៅខាងលើកម្ពស់១៥ស.ម ធ្វើពីលោហធាតុ ពណ៌ស។ ដងទង់ប្រវែង២៨៥ស.ម ធ្វើពីលោហធាតុ ឬឈើពណ៌ស មានទំហំអង្កត់ផ្ចិត ៤ស.ម។ មាន ០២ថ្នាក់៖

**ក.ទង់ជ័យ ថ្នាក់យុទ្ធសាស្ត្រ** បណ្តោយប្រវែង ១៧០ស.ម និងទទឹង១៣០ស.ម។ ឈ្មោះសមរភូមិ និងរូបសញ្ញា ត្រូវកំណត់ដោយ រាជរដ្ឋាភិបាល។

**ខ.ទង់ជ័យ ថ្នាក់យុទ្ធនាការ** បណ្តោយប្រវែង១៦៥ស.ម និងទទឹង១២៥ស.ម។ ឈ្មោះសមរភូមិ និងរូបសញ្ញា ត្រូវកំណត់ដោយក្រសួងការពារជាតិ ឬអគ្គបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ។

**+ ទង់ជ័យ កងយោធពលខេមរភូមិន្ទ ត្រូវរក្សាទុកនៅកន្លែងដែល អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទបានកំណត់។**

**២. ទង់ស្លាប័ន និងកងឯកភាព**

**២.១ ទង់កងយោធពលខេមរភូមិន្ទ**

រាងចតុកោណកែង បណ្តោយប្រវែង ១៧៨ស.ម និងទទឹង ១៣៥ស.ម ផ្ទៃទង់ពណ៌ក្រហម។ នៅចំកណ្តាលមានរូបសញ្ញា **កងយោធពលខេមរភូមិន្ទ** (រូបហនុមាន) ដែលមានកម្ពស់៩៧ស.ម និងទទឹង៦០ស.ម ពណ៌មាស នៅខាងក្រោមរូបសញ្ញាមានសរសេរអក្សរពណ៌មាស **កងយោធពលខេមរភូមិន្ទ** កម្ពស់អក្សរ១២ស.ម។ ដងទង់ប្រវែង២៨៥ស.ម ធ្វើពីលោហធាតុ ឬឈើ ពណ៌ស មានទំហំអង្កត់ផ្ចិត៤ស.ម។ ក្បាលដងទង់ខាងលើឆ្លាក់រូបព្រហ្មមុខបួន កម្ពស់២៥ស.ម ធ្វើពីលោហធាតុពណ៌មាស។ នៅក្បាលដងទង់មានរំយោលចងក្បាលដងទង់ពីរ ពណ៌មាស មួយប្រវែង៤០ស.ម និងមួយទៀតប្រវែង៥០ស.ម។ នៅជាយទង់មានរំយោលពណ៌មាសព័ទ្ធជុំវិញចំនួនបីជ្រុង រំយោលមានប្រវែង៣ស.ម។

**២.២ ទង់ក្រសួងការពារជាតិ**

រាងចតុកោណកែងបណ្តោយ ប្រវែង១៧៨ស.ម និងទទឹង ១៣៥ស.ម ផ្ទៃទង់ពណ៌ក្រហម ដូចទង់កងយោធពលខេមរភូមិន្ទ។ នៅផ្នែកខាងលើ ជ្រុងខាងឆ្វេងនៃផ្ទៃទង់មានរូបសញ្ញា **កងយោធពលខេមរភូមិន្ទ** (រូបហនុមាន) មានកម្ពស់ ៣៦ស.ម និងទទឹង២២ស.ម។ នៅចំកណ្តាលមានរូបសញ្ញា **ក្រសួងការពារជាតិ** ដែលមានកម្ពស់៦០ស.ម និងទទឹង៧៥ស.ម ពណ៌មាស នៅខាងក្រោមរូបសញ្ញាមានសរសេរអក្សរពណ៌មាស **ក្រសួងការពារជាតិ** កម្ពស់អក្សរ១២ស.ម។ ក្បាលដងទង់ រំយោលចងក្បាលដងទង់ ដងទង់ និងរំយោលជុំវិញទង់មានប្រវែង និងលក្ខណៈដូចទង់កងយោធពលខេមរភូមិន្ទ។

**២.៣ ទង់អគ្គបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ(ខ.ភ.ម)**

រាងចតុកោណកែងបណ្តោយប្រវែង១៧៨ស.ម និងទទឹង ១៣៥ស.ម ផ្ទៃទង់ពណ៌ក្រហម ដូចទង់កងយោធពលខេមរភូមិន្ទ។ នៅផ្នែកខាងលើ ជ្រុងខាងឆ្វេងនៃផ្ទៃទង់មានរូបសញ្ញា **កងយោធពល**



គេហទំព័រ ឯកសារមន្ត្រីរាជការ - https://t.me/oa_channel

**ខេមរភូមិន្ទ** (រូបហនុមាន) មានកម្ពស់ ៣៦ស.ម និងទទឹង២២ស.ម។ នៅចំកណ្តាលមានរូបសញ្ញា **អគ្គបញ្ជាការ** ដែលមានកម្ពស់ ៦២ស.ម និងទទឹង៧០ស.ម ពណ៌មាស នៅខាងក្រោមរូបសញ្ញាមានសរសេរអក្សរពណ៌មាស **អគ្គបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ(ខ.ភ.ម)** កម្ពស់អក្សរ ១២ស.ម។ ក្បាលដងទង់ រំយោលចងក្បាលដងទង់ ដងទង់និងរំយោលជុំវិញទង់មានប្រវែង និងលក្ខណៈដូចទង់កងយោធពលខេមរភូមិន្ទ។

**២.៤ ទង់ស្ថាប័ន និងកងឯកភាពចំណុះក្រសួងការពារជាតិមាន០៣ថ្នាក់៖**

**ក.ថ្នាក់ទី០១** មានទង់ **អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន សាកលវិទ្យាល័យ វិទ្យាស្ថាន និងកងឯកភាពប្រហាក់ប្រហែល** បណ្តោយប្រវែង ១៧០ស.ម និងទទឹង ១៣០ស.ម ផ្ទៃទង់ពណ៌ក្រហម ដូចទង់កងយោធពលខេមរភូមិន្ទ។ នៅផ្នែកខាងលើ ជ្រុងខាងឆ្វេងនៃផ្ទៃទង់មានរូបសញ្ញា**ក្រសួងការពារជាតិ** មានកម្ពស់២៨ស.ម និងទទឹង៣០ស.ម។ នៅចំកណ្តាលមានរូបសញ្ញាសម្គាល់ **កងឯកភាព** នៅខាងក្រោមរូបសញ្ញាមានសរសេរអក្សរពណ៌មាស ឈ្មោះ**កងឯកភាព** កម្ពស់អក្សរ ១១ស.ម។ ក្បាលដងទង់រាងជាសាជីស្រួចទៅខាងលើ កម្ពស់១៥ស.ម ធ្វើពីលោហធាតុ ពណ៌ស។ រូបរាងទង់ រំយោលចងក្បាលដងទង់ ដងទង់ និងរំយោលជុំវិញទង់មានប្រវែង និងលក្ខណៈដូចទង់កងយោធពលខេមរភូមិន្ទ។

**ខ.ថ្នាក់ទី០២** មានទង់ **នាយកដ្ឋាន មហាវិទ្យាល័យ សាលា និងកងឯកភាពប្រហាក់ប្រហែល** បណ្តោយប្រវែង ១៦៥ស.ម និងទទឹង ១២៥ស.ម។ នៅផ្នែកខាងលើជ្រុងខាងឆ្វេងនៃផ្ទៃទង់មានរូបសញ្ញា **ក្រសួងការពារជាតិ** មានកម្ពស់២៨ស.ម និងទទឹង៣០ស.ម។ នៅចំកណ្តាលមានរូបសញ្ញាសម្គាល់ **កងឯកភាព** នៅខាងក្រោមរូបសញ្ញាមានសរសេរអក្សរពណ៌មាស ឈ្មោះ**កងឯកភាព** កម្ពស់អក្សរ ១០ស.ម។ រូបរាងទង់ ពណ៌របស់ទង់ ក្បាលដងទង់ រំយោលចងក្បាលដងទង់ ដងទង់ និងរំយោលជុំវិញទង់មានប្រវែង និងលក្ខណៈដូចទង់កងឯកភាពចំណុះក្រសួងការពារជាតិថ្នាក់ទី១។

**គ.ថ្នាក់ទី០៣** មានទង់ **កងពលតូច និងកងឯកភាពប្រហាក់ប្រហែល** បណ្តោយប្រវែង១៦០ស.ម និងទទឹង១២២ស.ម។ នៅផ្នែកខាងលើជ្រុងខាងឆ្វេងនៃផ្ទៃទង់មានរូបសញ្ញា **ក្រសួងការពារជាតិ** មានកម្ពស់២៨ស.ម និងទទឹង៣០ស.ម។ នៅចំកណ្តាល មានរូបសញ្ញាសម្គាល់ **កងឯកភាព** នៅខាងក្រោមរូបសញ្ញាមានសរសេរអក្សរពណ៌មាស ឈ្មោះ**កងឯកភាព** កម្ពស់អក្សរ ១០ស.ម។ រូបរាងទង់ ពណ៌របស់ទង់ ក្បាលដងទង់ រំយោលចងក្បាលដងទង់ ដងទង់ និងរំយោលជុំវិញទង់មានប្រវែង និងលក្ខណៈដូចទង់កងឯកភាពចំណុះក្រសួងការពារជាតិថ្នាក់ទី០១។

**២.៥ ទង់ស្ថាប័ន និងកងឯកភាពចំណុះ អគ្គបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ មាន៣ថ្នាក់៖**

**ក.ថ្នាក់ទី០១** មានទង់ **ទីចាត់ការ បញ្ជាការដ្ឋានទ័ពជំនាញ វិទ្យាស្ថាន សាលា និងកងឯកភាពប្រហាក់ប្រហែល** បណ្តោយប្រវែង១៧០ស.ម និងទទឹង១៣០ស.ម ផ្ទៃទង់ពណ៌ក្រហម ដូចទង់កងយោធពលខេមរភូមិន្ទ។ នៅផ្នែកខាងលើជ្រុងខាងឆ្វេងនៃផ្ទៃទង់មានរូបសញ្ញា **អគ្គបញ្ជាការ** មានកម្ពស់២៦ស.ម និងទទឹង៣០ស.ម។ នៅចំកណ្តាលមានរូបសញ្ញាសម្គាល់ **កងឯកភាព** នៅខាងក្រោមរូបសញ្ញាមានសរសេរអក្សរពណ៌មាស ឈ្មោះ**កងឯកភាព** កម្ពស់អក្សរ ១១ស.ម។ ក្បាលដងទង់រាងជាសាជីស្រួចទៅខាងលើ កម្ពស់១៥ស.ម ធ្វើពីលោហធាតុពណ៌ស។ រូបរាងទង់ រំយោលចងក្បាលដងទង់ ដងទង់ និងរំយោលជុំវិញទង់មានប្រវែង និងលក្ខណៈដូចទង់កងយោធពលខេមរភូមិន្ទ។

**ខ.ថ្នាក់ទី០២** មានទង់ **មជ្ឈមណ្ឌល កងឯកភាព ដែលចំណុះឱ្យបញ្ជាការដ្ឋានទ័ពជំនាញ វិទ្យាស្ថាន សាលា និងកងឯកភាពប្រហាក់ប្រហែល** បណ្តោយប្រវែង ១៦៥ស.ម និងទទឹង១២៥ស.ម។ នៅផ្នែកខាងលើជ្រុងខាងឆ្វេងនៃផ្ទៃទង់ មានរូបសញ្ញា**អគ្គបញ្ជាការដ្ឋាន** មានកម្ពស់២៦ស.ម និងទទឹង៣០ស.ម។ នៅចំកណ្តាលមានរូបសញ្ញាសម្គាល់**កងឯកភាព** នៅខាងក្រោមរូបសញ្ញា មានសរសេរអក្សរពណ៌មាស ឈ្មោះ**កងឯកភាព** កម្ពស់អក្សរ១០ស.ម។ រូបរាងទង់ ពណ៌របស់ទង់ ក្បាលដងទង់ រំយោលចងក្បាលដងទង់ ដងទង់ និងរំយោលជុំវិញទង់មានប្រវែង និងលក្ខណៈដូចទង់កងឯកភាពចំណុះអគ្គបញ្ជាការនៃកងយោធពលខេមរភូមិន្ទថ្នាក់ទី០១។

**គ.ថ្នាក់ទី០៣** មានទង់ **វរសេនាតូច សាលា និងកងឯកភាពប្រហាក់ប្រហែលដែលចំណុះឱ្យបញ្ជាការដ្ឋានទ័ពជំនាញ** បណ្តោយប្រវែង ១៦០ស.ម និងទទឹង ១២២ស.ម។ នៅផ្នែកខាងលើជ្រុងខាងឆ្វេងនៃផ្ទៃទង់មានរូបសញ្ញា **អគ្គបញ្ជាការ** មានកម្ពស់២៦ស.ម និងទទឹង៣០ស.ម។ នៅចំកណ្តាលមានរូបសញ្ញាសម្គាល់ **កងឯកភាព** នៅខាងក្រោមរូបសញ្ញាមានសរសេរអក្សរពណ៌មាស ឈ្មោះ**កងឯកភាព** កម្ពស់អក្សរ ១០ស.ម។ រូបរាងទង់ពណ៌របស់ទង់ ក្បាលដងទង់ រំយោលចងក្បាលដងទង់ ដងទង់ និងរំយោលជុំវិញទង់មានប្រវែង និងលក្ខណៈដូចទង់កងឯកភាពចំណុះអគ្គបញ្ជាការ នៃកងយោធពលខេមរភូមិន្ទថ្នាក់ទី០១។

**២.៦ ទង់កងទ័ពជើងគោកមាន០៤ថ្នាក់៖**

**ក.ថ្នាក់ទី០១ គឺជាទង់បញ្ជាការដ្ឋានកងទ័ពជើងគោក** បណ្តោយប្រវែង ១៧០ស.ម និងទទឹង ១៣០ស.ម ផ្ទៃទង់ពណ៌ក្រហម ដូចទង់កងយោធពលខេមរភូមិន្ទ។ នៅផ្នែកខាងលើជ្រុងខាងឆ្វេងនៃផ្ទៃទង់មានរូបសញ្ញា **កងយោធពលខេមរភូមិន្ទ** (រូបហនុមាន) មានកម្ពស់៣៦ស.ម និងទទឹង ២២ស.ម។ នៅចំកណ្តាលមានរូបសញ្ញា **កងទ័ពជើងគោក** ដែលមានកម្ពស់៥៧ស.ម និងទទឹង៦៥ស.ម ពណ៌មាស នៅខាងក្រោមរូបសញ្ញាមានសរសេរអក្សរពណ៌មាស **កងទ័ពជើងគោក** កម្ពស់អក្សរ ១១ស.ម។ ក្បាលដងទង់រាងជាសាជីស្រួចទៅខាងលើកម្ពស់១៥ស.ម ធ្វើពីលោហធាតុពណ៌ស។ រូបរាងទង់ រំយោលចងក្បាលដងទង់ ដងទង់ និងរំយោលជុំវិញទង់មានប្រវែង និងលក្ខណៈដូចទង់កងយោធពលខេមរភូមិន្ទ។

**ខ.ថ្នាក់ទី០២** មានទង់ **យោធភូមិភាគ កងពលធំ បញ្ជាការដ្ឋាន ការិយាល័យចំណុះ កងទ័ពជើងគោក និងកងឯកភាពប្រហាក់ប្រហែល** បណ្តោយប្រវែង ១៦៥ស.ម និងទទឹង១,២៥ម៉ែត្រ។ នៅផ្នែកខាងលើជ្រុងខាងឆ្វេងនៃផ្ទៃទង់មានរូបសញ្ញា **កងទ័ពជើងគោក** ពណ៌មាស មានកម្ពស់២២ស.ម និងទទឹង២៥ស.ម។ នៅចំកណ្តាលមានរូបសញ្ញាសម្គាល់ **កងឯកភាព** នៅខាងក្រោមរូបសញ្ញា មានសរសេរអក្សរពណ៌មាស ឈ្មោះ**កងឯកភាព** កម្ពស់អក្សរ១០ស.ម។ រូបរាងទង់ ពណ៌របស់ទង់ ក្បាលដងទង់ រំយោលចងក្បាលដងទង់ ដងទង់ និងរំយោលជុំវិញទង់មានប្រវែង និងលក្ខណៈដូចទង់កងទ័ពជើងគោកថ្នាក់ទី០១។

**គ.ថ្នាក់ទី០៣** មានទង់ **កងពលតូច វរសេនាធំ កងការពារព្រំដែន តំបន់ប្រតិបត្តិការសឹករង មជ្ឈមណ្ឌលហ្វឹកហ្វឺនកងទ័ពជើងគោក និងកងឯកភាពប្រហាក់ប្រហែល** បណ្តោយប្រវែង ១៦០ស.ម និងទទឹង ១២២ស.ម។ នៅផ្នែកខាងលើ ជ្រុងខាងឆ្វេងនៃផ្ទៃទង់មានរូបសញ្ញា **កងទ័ពជើងគោក** ពណ៌មាស មានកម្ពស់២២ស.ម និងទទឹង២៥ស.ម។ នៅចំកណ្តាលមានរូបសញ្ញាសម្គាល់ **កងឯកភាព** នៅខាងក្រោមរូបសញ្ញាមានសរសេរអក្សរពណ៌មាស ឈ្មោះ**កងឯកភាព** កម្ពស់អក្សរ១០ស.ម។ រូបរាងទង់ ពណ៌របស់ទង់



រោងផ្ទះឯកសារមន្ត្រីរាជការ - https://t.me/oa_channel

ក្បាលដងទង់ រំយោលចងក្បាលដងទង់ ដងទង់ និងរំយោលជុំវិញទង់មានប្រវែង និងលក្ខណៈដូចទង់កងទ័ពជើងគោកថ្នាក់ទី០១។

**ឃ.ថ្នាក់ទី០៤** មានទង់ **វរសេនាតូច កងអនុសេនាធំ សាលាពលទាហាន និងកងឯកភាពប្រហាក់ប្រហែល** បណ្តោយប្រវែង ១៥៣ស.ម និងទទឹង ១១៧ស.ម។ នៅផ្នែកខាងលើជ្រុងខាងឆ្វេងនៃផ្ទៃទង់មានរូបសញ្ញា **កងទ័ពជើងគោក** ពណ៌មាស មានកម្ពស់២២ស.ម និងទទឹង២៥ស.ម។ នៅចំកណ្តាលមានរូបសញ្ញាសម្គាល់ **កងឯកភាព** នៅខាងក្រោមរូបសញ្ញាមានសរសេរអក្សរពណ៌មាសឈ្មោះ **កងឯកភាព** កម្ពស់អក្សរ១០ស.ម។ រូបរាងទង់ ពណ៌របស់ទង់ ក្បាលដងទង់ រំយោលចងក្បាលដងទង់ ដងទង់ និងរំយោលជុំវិញទង់ មានប្រវែង និងលក្ខណៈដូចទង់កងទ័ពជើងគោកថ្នាក់ទី០១។

**២.៧ ទង់កងទ័ពជើងទឹកមាន០៣ថ្នាក់៖**

**ក.ថ្នាក់ទី០១ គឺជាទង់បញ្ជាការដ្ឋានកងទ័ពជើងទឹក** បណ្តោយប្រវែង១៧០ស.ម និងទទឹង១៣០ស.ម ផ្ទៃទង់ពណ៌ខៀវទឹកសមុទ្រ។ នៅផ្នែកខាងលើជ្រុងខាងឆ្វេងនៃផ្ទៃទង់មានរូបសញ្ញា **កងយោធពលខេមរភូមិន្ទ** (រូបហនុមាន) មានកម្ពស់៣៦ស.ម និងទទឹង២២ស.ម។ នៅចំកណ្តាលមានរូបសញ្ញា **កងទ័ពជើងទឹក** ដែលមានកម្ពស់៨៨ស.ម និងទទឹង៧០ស.ម ពណ៌មាស នៅខាងក្រោមរូបសញ្ញាមានសរសេរអក្សរពណ៌មាស **កងទ័ពជើងទឹក** កម្ពស់អក្សរ ១១ស.ម។ ក្បាលដងទង់រាងជាសាជីស្រួចទៅខាងលើកម្ពស់១៥ស.ម ធ្វើពីលោហធាតុពណ៌ស។ រូបរាងទង់ រំយោលចងក្បាលដងទង់ ដងទង់ និងរំយោលជុំវិញទង់មានប្រវែង និងលក្ខណៈដូចទង់កងយោធពលខេមរភូមិន្ទ។

**ខ.ថ្នាក់ទី០២** មានទង់ **មូលដ្ឋានសមុទ្រ បញ្ជាការដ្ឋានការពារ កោះ ឆ្នេរ ស្នងការ វិទ្យាស្ថានកងទ័ពជើងទឹក និងកងឯកភាពប្រហាក់ប្រហែល**បណ្តោយប្រវែង១៦៥ស.ម និងទទឹង ១២៥ស.ម។ នៅផ្នែកខាងលើជ្រុងខាងឆ្វេងនៃផ្ទៃទង់មានរូបសញ្ញា**កងទ័ពជើងទឹក** មានកម្ពស់២០ស.ម និងទទឹង៣០ស.ម។ នៅចំកណ្តាលមានរូបសញ្ញាសម្គាល់ **កងឯកភាព** នៅខាងក្រោមរូបសញ្ញាមានសរសេរអក្សរពណ៌មាសឈ្មោះ**កងឯកភាព** កម្ពស់អក្សរ១០ស.ម។ រូបរាងទង់ ពណ៌របស់ទង់ ក្បាលដងទង់ រំយោលចងក្បាលដងទង់ ដងទង់ និងរំយោលជុំវិញទង់ មានប្រវែង និងលក្ខណៈដូចទង់កងទ័ពជើងទឹកថ្នាក់ទី០១។

**គ.ថ្នាក់ទី០៣** មានទង់**កងឯកភាពចំណុះបញ្ជាការដ្ឋាន ចំណុះមូលដ្ឋានសមុទ្រ ចំណុះបញ្ជាការដ្ឋានការពារ កោះ ឆ្នេរ និងកងឯកភាពប្រហាក់ប្រហែល** បណ្តោយប្រវែង ១៦០ស.ម និងទទឹង ១២២ស.ម។ នៅផ្នែកខាងលើជ្រុងខាងឆ្វេងនៃផ្ទៃទង់មានរូបសញ្ញា **កងទ័ពជើងទឹក** មានកម្ពស់២០ស.ម និងទទឹង៣០ស.ម។ នៅចំកណ្តាលមានរូបសញ្ញាសម្គាល់ **កងឯកភាព** នៅខាងក្រោមរូបសញ្ញាមានសរសេរអក្សរពណ៌មាសឈ្មោះ**កងឯកភាព** កម្ពស់អក្សរ១០ស.ម។ រូបរាងទង់ ពណ៌របស់ទង់ ក្បាលដងទង់ រំយោលចងក្បាលដងទង់ ដងទង់ និងរំយោលជុំវិញទង់ មានប្រវែង និងលក្ខណៈដូចទង់កងទ័ពជើងទឹកថ្នាក់ទី០១។

**២.៨ ទង់កងទ័ពជើងអាកាសមាន០៣ថ្នាក់៖**

**ក.ថ្នាក់ទី០១ គឺជាទង់បញ្ជាការដ្ឋានកងទ័ពជើងអាកាស** បណ្តោយប្រវែង ១៧០ស.ម និងទទឹង១៣០ស.ម ផ្ទៃទង់ពណ៌ខៀវផ្ទៃមេឃ។ នៅផ្នែកខាងលើជ្រុងខាងឆ្វេងនៃផ្ទៃទង់មានរូបសញ្ញា **កងយោធពលខេមរភូមិន្ទ** (រូបហនុមាន) មានកម្ពស់ ៣៦ស.ម និងទទឹង២២ស.ម។ នៅចំកណ្តាលមានរូបសញ្ញា **កងទ័ពជើងអាកាស** ដែលមានកម្ពស់៨៣ស.ម និងទទឹង៨៥ស.ម ពណ៌មាស នៅខាងក្រោមរូបសញ្ញាមានសរសេរអក្សរពណ៌មាស **កងទ័ពជើងអាកាស** កម្ពស់អក្សរ១១ស.ម។ ក្បាលដងទង់រាងជា

សាជីស្រួចទៅខាងលើ កម្ពស់១៥ស.ម ធ្វើពីលោហធាតុ ពណ៌ស។ រូបរាងទង់ រំយោលចងក្បាលដងទង់ ដងទង់ និងរំយោលជុំវិញទង់មានប្រវែង និងលក្ខណៈដូចទង់កងយោធពលខេមរភូមិន្ទ។

**ខ.ថ្នាក់ទី០២** មានទង់ **ស្នងការ មូលដ្ឋានទ័ពអាកាស បញ្ជាការដ្ឋានកងទ័ពជើងអាកាស វិទ្យាស្ថានកងទ័ពជើងអាកាស និងកងឯកភាពប្រហាក់ប្រហែល** បណ្តោយប្រវែង ១៦៥ស.ម និងទទឹង ១២៥ស.ម។ នៅផ្នែកខាងលើជ្រុងខាងឆ្វេងនៃផ្ទៃទង់មានរូបសញ្ញា **កងទ័ពជើងអាកាស** ពណ៌មាស មានកម្ពស់១៨ស.ម និងទទឹង៣៥ស.ម។ នៅចំកណ្តាលមានរូបសញ្ញាសម្គាល់ **កងឯកភាព** នៅខាងក្រោមរូបសញ្ញាមានសរសេរអក្សរពណ៌មាស ឈ្មោះ**កងឯកភាព** កម្ពស់អក្សរ១០ស.ម។ រូបរាងទង់ ពណ៌របស់ទង់ ក្បាលដងទង់ រំយោលចងក្បាលដងទង់ ដងទង់ និងរំយោលជុំវិញទង់ មានប្រវែង និងលក្ខណៈដូចទង់កងទ័ពជើងអាកាសថ្នាក់ទី០១។

**គ.ថ្នាក់ទី០៣** មានទង់ **អង្គភាពចំណុះបញ្ជាការដ្ឋាន ចំណុះមូលដ្ឋានទ័ពអាកាស កងអន្តរាគមន៍ និងកងឯកភាពប្រហាក់ប្រហែល**បណ្តោយប្រវែង ១៦០ស.ម និងទទឹង ១២២ស.ម។ នៅផ្នែកខាងលើជ្រុងខាងឆ្វេងនៃផ្ទៃទង់មានរូបសញ្ញា **កងទ័ពជើងអាកាស**ពណ៌មាស មានកម្ពស់១៨ស.ម និងទទឹង៣៥ស.ម។ នៅចំកណ្តាលមានរូបសញ្ញាសម្គាល់**កងឯកភាព** នៅខាងក្រោមរូបសញ្ញា មានសរសេរអក្សរពណ៌មាស ឈ្មោះ**កងឯកភាព** កម្ពស់អក្សរ ១០ស.ម។ រូបរាងទង់ ពណ៌របស់ទង់ ក្បាលដងទង់ រំយោលចងក្បាលដងទង់ ដងទង់ និងរំយោលជុំវិញទង់ មានប្រវែង និងលក្ខណៈដូចទង់កងទ័ពជើងអាកាសថ្នាក់ទី០១។

**២.៩ ទង់កងរាជអាវុធហត្ថមាន០៤ថ្នាក់៖**

**ក.ថ្នាក់ទី០១គឺជាទង់កងរាជអាវុធហត្ថលើផ្ទៃប្រទេស**បណ្តោយប្រវែង១៧០ស.ម និងទទឹង១៣០ស.ម ផ្ទៃទង់ពណ៌ខៀវទឹកប៊ិកចាស់។ នៅផ្នែកខាងលើជ្រុងខាងឆ្វេងនៃផ្ទៃទង់មានរូបសញ្ញា **កងយោធពលខេមរភូមិន្ទ** (រូបហនុមាន) មានកម្ពស់៣៦ស.ម និងទទឹង២២ស.ម។ នៅចំកណ្តាលមានរូបសញ្ញា **កងរាជអាវុធហត្ថ** ដែលមានអង្កត់ផ្ចិត៥០ស.ម នៅខាងក្រោមរូបសញ្ញា មានសរសេរអក្សរពណ៌មាស **កងរាជអាវុធហត្ថលើផ្ទៃប្រទេស** កម្ពស់អក្សរ១១ស.ម។ ក្បាលដងទង់រាងជាសាជីស្រួចទៅខាងលើ កម្ពស់១៥ស.ម ធ្វើពីលោហធាតុ ពណ៌ស។ រូបរាងទង់ រំយោលចងក្បាលដងទង់ ដងទង់ និងរំយោលជុំវិញទង់មានប្រវែង និងលក្ខណៈដូចទង់កងយោធពលខេមរភូមិន្ទ។

**ខ.ថ្នាក់ទី០២** មានទង់ **វិទ្យាស្ថានកងរាជអាវុធហត្ថ មជ្ឈមណ្ឌលហ្វឹកហ្វឺន ភ្នំជុំសែនរីករាយ ស្នងការ និងកងឯកភាពប្រហាក់ប្រហែល** បណ្តោយប្រវែង ១៦៥ស.ម និងទទឹង ១២៥ស.ម។ នៅផ្នែកខាងលើជ្រុងខាងឆ្វេងនៃផ្ទៃទង់ មានរូបសញ្ញា **កងរាជអាវុធហត្ថ** មានអង្កត់ផ្ចិត ២២ស.ម។ នៅចំកណ្តាលមានរូបសញ្ញាសម្គាល់ **កងឯកភាព** នៅខាងក្រោមរូបសញ្ញាមានសរសេរអក្សរពណ៌មាស ឈ្មោះ**កងឯកភាព** កម្ពស់អក្សរ ១០ស.ម។ រូបរាងទង់ ពណ៌របស់ទង់ ក្បាលដងទង់ រំយោលចងក្បាលដងទង់ ដងទង់ និងរំយោលជុំវិញទង់ មានប្រវែង និងលក្ខណៈដូចទង់កងរាជអាវុធហត្ថថ្នាក់ទី០១។

**គ.ថ្នាក់ទី០៣** មានទង់ **បញ្ជាការដ្ឋានកងរាជអាវុធហត្ថ រាជធានី-ខេត្ត និងកងឯកភាពប្រហាក់ប្រហែល** បណ្តោយប្រវែង ១៦០ស.ម និងទទឹង ១២២ស.ម។ នៅផ្នែកខាងលើជ្រុងខាងឆ្វេងនៃផ្ទៃទង់ មានរូបសញ្ញា **កងរាជអាវុធហត្ថ** មានអង្កត់ផ្ចិត២២ស.ម។ នៅចំកណ្តាលមានរូបសញ្ញាសម្គាល់ **កងឯកភាព** នៅខាងក្រោមរូបសញ្ញាមានសរសេរអក្សរពណ៌មាស ឈ្មោះ**កងឯកភាព** កម្ពស់អក្សរ១០ស.ម។ រូបរាង



គេហទំព័រ ឯកសារអេឡិចត្រូនិក - https://t.me/oa_channel

ទង់ពណ៌របស់ទង់ ក្បាលដងទង់ រំយោលចងក្បាលដងទង់ ដងទង់ និងរំយោលជុំវិញទង់មានប្រវែង និងលក្ខណៈដូចទង់កងរាជអាវុធហត្ថថ្នាក់ទី០១។

**ឃ.ថ្នាក់ទី០៤** មានទង់ **កងរាជអាវុធហត្ថចល័ត វរអន្តរាគមន៍ កងអន្តរាគមន៍ និងកងឯកភាពប្រហាក់ប្រហែល** បណ្ដោយប្រវែង ១៥៣ស.ម និងទទឹង ១១៧ស.ម។ នៅផ្នែកខាងលើជ្រុងខាងឆ្វេងនៃផ្ទៃទង់មានរូបសញ្ញា **កងរាជអាវុធហត្ថ** មានអង្កត់ផ្ចិត២២ស.ម។ នៅចំកណ្ដាលមានរូបសញ្ញាសម្គាល់ **កងឯកភាព** នៅខាងក្រោមរូបសញ្ញាមានសរសេរអក្សរពណ៌មាស ឈ្មោះ **កងឯកភាព** កម្ពស់អក្សរ១០ស.ម។ រូបរាងទង់ ពណ៌របស់ទង់ ក្បាលដងទង់ រំយោលចងក្បាលដងទង់ ដងទង់ និងរំយោលជុំវិញទង់ មានប្រវែង និងលក្ខណៈដូចទង់កងរាជអាវុធហត្ថថ្នាក់ទី០១។

**២.១០ ទង់បញ្ជាការដ្ឋានអង្គរក្សមាន០៣ថ្នាក់៖**

**ក.ថ្នាក់ទី០១ គឺជា ទង់បញ្ជាការដ្ឋានអង្គរក្ស** បណ្ដោយប្រវែង ១៧០ស.ម និងទទឹង ១៣០ស.ម ផ្ទៃទង់ពណ៌ក្រហម ដូចទង់កងយោធពលខេមរភូមិន្ទ។ នៅផ្នែកខាងលើជ្រុងខាងឆ្វេងនៃផ្ទៃទង់ មានរូបសញ្ញា **កងយោធពលខេមរភូមិន្ទ** (រូបហនុមាន) មានកម្ពស់៣៦ស.ម និងទទឹង២២ស.ម។ នៅចំកណ្ដាលមានរូបសញ្ញា **បញ្ជាការដ្ឋានអង្គរក្ស** ដែលមានអង្កត់ផ្ចិត៥០ស.ម នៅខាងក្រោមរូបសញ្ញាមានសរសេរអក្សរពណ៌មាស **បញ្ជាការដ្ឋានអង្គរក្ស** កម្ពស់អក្សរ១១ស.ម។ ក្បាលដងទង់រាងជាសាជីស្រួចទៅខាងលើកម្ពស់១៥ស.ម ធ្វើពីលោហធាតុ ពណ៌ស។ រូបរាងទង់ រំយោលចងក្បាលដងទង់ ដងទង់ និងរំយោលជុំវិញទង់មានប្រវែង និងលក្ខណៈដូចទង់កងយោធពលខេមរភូមិន្ទ។

**ខ.ថ្នាក់ទី០២** មានទង់ **មជ្ឈមណ្ឌលហ្វឹកហ្វឺន ស្នងការ និងកងឯកភាពប្រហាក់ប្រហែល** បណ្ដោយប្រវែង ១៦៥ស.ម និងទទឹង ១២៥ស.ម។ នៅផ្នែកខាងលើជ្រុងខាងឆ្វេងនៃផ្ទៃទង់មានរូបសញ្ញា **បញ្ជាការដ្ឋានអង្គរក្ស** មានអង្កត់ផ្ចិត២២ស.ម។ នៅចំកណ្ដាលមានរូបសញ្ញាសម្គាល់ **កងឯកភាព** នៅខាងក្រោមរូបសញ្ញាមានសរសេរអក្សរពណ៌មាស ឈ្មោះ**កងឯកភាព** កម្ពស់អក្សរ១០ស.ម។ រូបរាងទង់ ពណ៌របស់ទង់ ក្បាលដងទង់ រំយោលចងក្បាលដងទង់ ដងទង់ និងរំយោលជុំវិញទង់មានប្រវែង និងលក្ខណៈដូចទង់បញ្ជាការដ្ឋានអង្គរក្សថ្នាក់ទី០១។

**គ.ថ្នាក់ទី០៣** មានទង់ **វរសេនាតូចអន្តរាគមន៍ កងអន្តរាគមន៍ពិសេស និងកងឯកភាពប្រហាក់ប្រហែល** បណ្ដោយប្រវែង ១៦០ស.ម និងទទឹង ១២២ស.ម។ នៅផ្នែកខាងលើជ្រុងខាងឆ្វេងនៃផ្ទៃទង់មានរូបសញ្ញា **បញ្ជាការដ្ឋានអង្គរក្ស** មានអង្កត់ផ្ចិត២២ស.ម។ នៅចំកណ្ដាលមានរូបសញ្ញាសម្គាល់ **កងឯកភាព** នៅខាងក្រោមរូបសញ្ញាមានសរសេរអក្សរ ពណ៌មាស ឈ្មោះ **កងឯកភាព** កម្ពស់អក្សរ១០ស.ម។ រូបរាងទង់ ពណ៌របស់ទង់ ក្បាលដងទង់ រំយោលចងក្បាលដងទង់ ដងទង់ និងរំយោលជុំវិញទង់មានប្រវែង និងលក្ខណៈដូចទង់បញ្ជាការដ្ឋានអង្គរក្សថ្នាក់ទី០១។

**២.១១ ទង់ប្រចាំវគ្គសិក្សា**

**ទង់ប្រចាំវគ្គសិក្សា** ជាទង់សម្រាប់ប្រគល់ជូន **វគ្គបណ្ដុះបណ្ដាល ជំនាន់សិក្សានីមួយៗ** រាងចតុកោណកែងបណ្ដោយប្រវែង ១៦០ស.ម និងទទឹង ១២២ស.ម ផ្ទៃទង់ពណ៌ក្រហម ដូចទង់កងយោធពលខេមរភូមិន្ទ។ នៅផ្នែកខាងលើ ជ្រុងខាងឆ្វេងនៃផ្ទៃទង់ មានរូបសញ្ញា **តាមវិទ្យាស្ថាន ឬសាលានីមួយៗ។** នៅចំកណ្ដាលមាន **រូបសញ្ញា ប្រចាំវគ្គសិក្សា (ជំនាន់) នីមួយៗប្រគល់ជូន** នៅខាងក្រោមរូបសញ្ញាមានសរសេរអក្សរពណ៌មាស **ឈ្មោះវគ្គសិក្សា (ជំនាន់សិក្សា)** កម្ពស់អក្សរ១០ស.ម។ ក្បាលដងទង់រាងជា

សាជីស្រួចទៅខាងលើកម្ពស់១៥ស.ម ធ្វើពីលោហធាតុពណ៌ស។ ដងទង់មានប្រវែង និងលក្ខណៈដូចទង់កងយោធពលខេមរភូមិន្ទ។

ទង់នេះ ត្រូវរក្សាទុកនៅគ្រឹះស្ថានសិក្សា វិទ្យាស្ថាន ឬសាលាដែលបានសិក្សា។

បែបបទនៃការប្រើប្រាស់សញ្ញាសម្គាល់សម្រាប់ដាក់លើទង់របស់បណ្ដាស្ថាប័ន កងឯកភាពចំណុះក្រសួងការពារជាតិ អគ្គបញ្ជាការដ្ឋាន ប្រភេទទ័ព កងរាជអាវុធហត្ថលើផ្ទៃប្រទេស បញ្ជាការដ្ឋានកងអង្គរក្ស ទ័ពជំនាញ និងសញ្ញាប្រចាំវគ្គសិក្សា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ។

កងឯកភាពមិនទាន់មានសញ្ញាសម្គាល់ ត្រូវធ្វើសំណើមកក្រសួងការពារជាតិពិនិត្យសម្រេច។

រូបភាពទង់កងយោធពលខេមរភូមិន្ទ មានគំរូដូចក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រាពីរ.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រាបី.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៧រោច ខែ ភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ តុលា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្ដីគោរពជម្រាបជូន

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**នាយករដ្ឋមន្ត្រី** សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្ដមសេនីយ៍ ទៀ សីហា**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតី នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រាបី
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



គេហទំព័រ ឯកសារផ្លូវការ: - https://t.me/oa_channel

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ......៣០៤ អនក្រ.បក......ចុះថ្ងៃទី......៦......ខែ......តុលា......ឆ្នាំ២០២៣

**ស្តីពី ការកែសម្រួល មាត្រា៣២ មាត្រា៣៦ និងមាត្រា៤០ នៃអនុក្រឹត្យលេខ១២ អនក្រ.បក ចុះថ្ងៃទី០១ ខែ**
កុម្ភៈ ឆ្នាំ២០១៧ និងមាត្រា ១៣ថ្មី នៃអនុក្រឹត្យលេខ២២១ អនក្រ.បក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីឯកសណ្ឋាន ស្លាកសញ្ញា និងទង់ជ័យនៃកងយោធពលខេមរភូមិន្ទ

**១- ឯកសណ្ឋានលេខ៤ កងទ័ពជើងទឹក**



## ២- មួកកាស្កេតនារី

### មួកកាស្កេតនារី កងទ័ពជើងគោក

| ឧត្តមសេនីយ៍ | វរសេនីយ៍ | អនុសេនីយ៍ | នាយទាហានរង និងពលទាហាន |
|---|---|---|---|



### មួកកាស្កេតនារី កងទ័ពជើងទឹក

| ឧត្តមនាវី | វរនាវី | អនុនាវី | នាយនាវីរង និងពលនាវី |
|---|---|---|---|



### មួកកាស្កេតនារី កងទ័ពជើងអាកាស

| ឧត្តមសេនីយ៍ | វរសេនីយ៍ | អនុសេនីយ៍ | នាយទាហានរង និងពលទាហាន |
|---|---|---|---|



### មួកកាស្កេតនារី កងរាជអាវុធហត្ថ

| ឧត្តមសេនីយ៍ | វរសេនីយ៍ | អនុសេនីយ៍ | នាយទាហានរង និងពលទាហាន |
|---|---|---|---|



តេឡេក្រាម ឯកសារមន្ត្រីរាជការ: - https://t.me/oa_channel

## ៣- ឯកសណ្ឋានសិល្បៈ កងយោធពលខេមរភូមិន្ទ

### ឯកសណ្ឋានកកុដ

ចុងដៃអាវ




ក្បាលខ្សែក្រវ៉ាត់



សក្តិស្មា



ខោ និងសំពត់មើលពីចំហៀង






### ឯកសណ្ឋានសាហារីយែន



## ៤- ឯកសណ្ឋានលេខ៥ ពណ៌ខៀវទឹកប៊ិចចាស់ កងរាជអាវុធហត្ថ

### មួកបេរ៉េ

ឧត្តមសេនីយ៍ | វរសេនីយ៍ | អនុសេនីយ៍ | នាយទាហានរង និង ពលទាហាន



### មួកដែក

ឧត្តមសេនីយ៍ | វរសេនីយ៍ | អនុសេនីយ៍ | នាយទាហានរង និង ពលទាហាន



តេឡេក្រាម ឯកសារមន្ត្រីសាធារណៈ - https://t.me/oa_channel

**មួកហាម**

ឧត្តមសេនីយ៍ | វរសេនីយ៍ | អនុសេនីយ៍ | នាយទាហានរង និង ពលទាហាន



**៥- ទង់ជ័យ កងយោធពលខេមរភូមិន្ទ** មាន០២ថ្នាក់៖

ទង់ជ័យ ថ្នាក់យុទ្ធសាស្ត្រ




ទង់ជ័យ ថ្នាក់យុទ្ធនាការ



## ៦- ទង់ស្ថាប័ន និងកងឯកភាព

ទង់កងយោធពលខេមរភូមិន្ទ




ទង់ក្រសួងការពារជាតិ




ទង់អគ្គបញ្ជាការ នៃខ.ភ.ម




https://t.me/oa_channel

### ៧- ទង់ស្ថាប័ន និងកងឯកភាព ចំណុះក្រសួងការពារជាតិ មាន០៣ថ្នាក់៖

ថ្នាក់ទី០១




ថ្នាក់ទី០២




ថ្នាក់ទី០៣



## ៨- ទង់ស្ថាប័ន និងកងឯកភាព ចំណុះអគ្គបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ

មាន០៣ថ្នាក់៖

ថ្នាក់ទី០១




ថ្នាក់ទី០២




ថ្នាក់ទី០៣




គេហទំព័រ ឯកសារមន្ត្រីរាជការ: - https://t.me/oa_channel

### ៩- ទង់កងទ័ពជើងគោក មាន០៤ថ្នាក់៖

ថ្នាក់ទី០១




ថ្នាក់ទី០២




ថ្នាក់ទី០៣




ថ្នាក់ទី០៤



## ១០-ទង់កងទ័ពជើងទឹក មាន០៣ថ្នាក់៖

ថ្នាក់ទី០១




ថ្នាក់ទី០២




ថ្នាក់ទី០៣




https://t.me/oa_channel

## ១១-ទង់កងទ័ពជើងអាកាស មាន០៣ថ្នាក់៖

ថ្នាក់ទី០១




ថ្នាក់ទី០២




ថ្នាក់ទី០៣



**១២- ធង់កងរាជអាវុធហត្ថ** មាន០៤ថ្នាក់៖

ថ្នាក់ទី០១




ថ្នាក់ទី០២




ថ្នាក់ទី០៣




ថ្នាក់ទី០៤




គេហទំព័រ ឯកសារមន្ត្រីរាជការ: - https://t.me/oa_channel

**១៣- ទង់បញ្ជាការដ្ឋានអង្គរក្ស** មាន០៣ថ្នាក់៖

ថ្នាក់ទី០១




ថ្នាក់ទី០២




ថ្នាក់ទី០៣



## ១៤- ទង់ប្រចាំវគ្គសិក្សា




- https://t.me/oa_channel